# តើអារក្សជាអ្នកណា ?

*អារក្សសាតាំង—តើវាកើតមកពីណា? (១, ២)*

*តើតាមរបៀបណាដែលសាតាំងនាំមនុស្សឲ្យវង្វេង? (៣-៧)*

*ហេតុអ្វីអ្នកត្រូវទប់ទល់នឹងអារក្ស? (៧)*



១. ពាក្យ «អារក្ស» មានន័យថាអ្នកដែលប្រាប់ពាក្យកុហកដ៏អាក្រក់អំពីបុគ្គលម្នាក់ទៀត ។ «សាតាំង» មានន័យថា សត្រូវឬអ្នកប្រឆាំង ។ ពាក្យទាំងនេះជាពាក្យប្រើសំរាប់មេសត្រូវនៃព្រះ ។ ដំបូងបុគ្គលនេះជាទេវតាគ្រប់លក្ខណ៍មួយរូប ដែលគង់នៅក្នុងស្ថានសួគ៌ជាមួយនឹងព្រះ ។ ប៉ុន្តែ ក្រោយមកវាគិតគូរច្រើនហួសហេតុពេកអំពីផលប្រយោជន៍ផ្ទាល់ខ្លួន ហើយចង់បានការថ្វាយបង្គំដែលជារបស់ផងព្រះយ៉ាងត្រឹមត្រូវ ។—ម៉ាថាយ ៤:៨-១០

២. ទេវតានេះ គឺសាតាំង បាននិយាយទៅកាន់នាងអេវ៉ាតាមរយៈសត្វពស់មួយ ។ ដោយប្រាប់ពាក្យកុហកដល់នាង វាបានធ្វើឲ្យនាងមិនស្តាប់បង្គាប់ព្រះ ។ ដូច្នេះសាតាំងបានប្រឆាំងរុករានលើអ្វីដែលហៅថា «ព្រះអធិបតេយ្យភាព» របស់ព្រះ ឬតំណែងជាព្រះដ៏ខ្ពស់បំផុត ។ សាតាំងបានចោទសួរថាតើព្រះទ្រង់គ្រងក្នុងរបៀបដ៏សមល្អឬ ហើយឲ្យបានផលប្រយោជន៍ល្អបំផុតដល់អនុរាស្ត្រនៃទ្រង់មែនឬទេ ។ សាតាំងក៏បានលើកការសង្ស័យឡើងដែរ ដោយសួរថាតើនឹងមានមនុស្សលោកណាដែលនៅស្មោះត្រង់ចំពោះព្រះជានិច្ច ។ ដោយធ្វើដូច្នេះ សាតាំងបានលើកខ្លួនជាសត្រូវរបស់ព្រះ ។ ដូច្នេះហើយបានជាគេហៅវាថា អារក្សសាតាំង ។—លោកុប្បត្តិ ៣:១-៥; យ៉ូប ១:៨-១១; វិវរណៈ ១២:៩

៣. សាតាំងខំប្រើល្បិចបញ្ឆោតមនុស្សឲ្យថ្វាយបង្គំវា ។ (កូរិនថូសទី២ ១១:៣, ១៤) វិធីមួយដែលវានាំមនុស្សឲ្យវង្វេងគឺដោយប្រើ*សាសនាក្លែងក្លាយ* ។ បើសាសានាណាបង្រៀនពាក្យកុហកអំពីព្រះ នោះគឺពិតជាបំពេញគោលបំណងរបស់សាតាំងហើយ ។ (យ៉ូហាន ៨:៤៤) មនុស្សដែលជាសមាជិកនៃសាសនាក្លែងក្លាយប្រហែលជាជឿដោយស្មោះពីចិត្តថាគេកំពុងថ្វាយបង្គំព្រះពិត ។ ប៉ុន្តែពួកគេតាមពិតគឺបំរើសាតាំងវិញ ។ វាជា‹ព្រះរបស់លោកីយនេះ› ។—កូរិនថូសទី២ ៤:៤

៤. *មន្តអាគម* គឺជាវិធីមួយទៀតដែលសាតាំងប្រើដើម្បីទាញមនុស្សឲ្យចូលក្រោមអំណាចរបស់វា ។ ពួកគេប្រហែលអំពាវនាវហៅពួកវិញ្ញាណឲ្យការពារគេ ឲ្យធ្វើទុក្ខដល់មនុស្សឯទៀត ទាយអំពីអនាគត ឬធ្វើអព្ភូតហេតុ ។ សាតាំងគឺជាកម្លាំងដ៏កំណាចដែលនៅពីក្រោយ គាំទ្រការប្រព្រឹត្តទាំងនេះ ។ ដើម្បីផ្គាប់ព្រះហឫទ័យនៃព្រះ យើងត្រូវតែកុំប៉ះពាល់នឹងមន្តអាគមឲ្យសោះ ។—ចោទិយកថា ១៨:១០-១២; កិច្ចការ ១៩:១៨, ១៩

៥. សាតាំងក៏នាំមនុស្សឲ្យវង្វេងដែរ ដោយប្រើ*សេចក្តីក្រអឺតក្រអាងពូជសាសន៍ហួសហេតុ* និងប្រើ*ការថ្វាយបង្គំអង្គការនយោបាយ* ។ មនុស្សខ្លះយល់ថាជាតិឬពូជសាសន៍របស់គេគឺល្អប្រសើរជាងជាតិឬពូជសាសន៍ឯ



*សាសនាក្លែងក្លាយ មន្តអាគម និង ជាតិនិយមនាំមនុស្សឲ្យវង្វេង*

ទៀត ។ ប៉ុន្តែនេះគឺមិនពិតទេ ។ (កិច្ចការ ១០:៣៤, ៣៥) មនុស្សឯទៀតពឹងផ្អែកលើអង្គការនយោបាយឲ្យដោះស្រាយវិបត្តិមនុស្សជាតិ ។ ដោយធ្វើដូច្នេះ ពួកគេបដិសេធចោលព្រះរាជាណាចក្រនៃព្រះ ។ គឺមានតែព្រះរាជាណាចក្រនៃព្រះប៉ុណ្ណោះទេ ដែលអាចដោះស្រាយវិបត្តិរបស់យើងបាន ។—ដានីយ៉ែល ២:៤៤

៦. វិធីមួយទៀតដែលសាតាំងនាំមនុស្សឲ្យវង្វេងគឺដោយប្រើ *សេចក្ដីប៉ងប្រាថ្នាដ៏មានបាប* មកល្បួងគេ ។ ព្រះយេហូវ៉ាមានបន្ទូលប្រាប់យើងឲ្យជៀសវាងការប្រព្រឹត្តដ៏មានបាប ពីព្រោះទ្រង់ដឹងថាការទាំងនេះនឹងនាំផលអាក្រក់ដល់យើង ។ (កាឡាទី ៦:៧, ៨) មនុស្សខ្លះប្រហែលចង់ឲ្យអ្នកចូលរួមជាមួយពួកគេក្នុងការប្រព្រឹត្តបែបនេះ ។ ប៉ុន្តែសូមចាំថា គឺពិតជាសាតាំងទេ ដែលចង់ឲ្យអ្នកប្រព្រឹត្តការទាំងនេះ ។—កូរិនថូសទី១ ៦:៩, ១០; ១៥:៣៣

៧. សាតាំងប្រហែលប្រើ *ការធ្វើទុក្ខបៀតបៀន* ឬ *ការប្រឆាំង* ដើម្បីធ្វើឲ្យអ្នកចាកចេញពីព្រះយេហូវ៉ា ។ បងប្អូនញាតិមិត្តជាទីស្រឡាញ់ខ្លះរបស់អ្នក ប្រហែលទៅជាខឹងណាស់ពីព្រោះអ្នកសិក្សាព្រះគម្ពីរ ។ អ្នកឯទៀតប្រហែលជាចំអកដាក់អ្នក ។ ប៉ុន្តែ តើអ្នកបានជីវិតមកដោយសារអ្នកណាគេ ? សាតាំងចង់បន្លាចអ្នកដើម្បីឲ្យអ្នកឈប់រៀនអំពីព្រះយេហូវ៉ាទៀត ។ សូមកុំឲ្យសាតាំងបានជ័យជំនះឡើយ ! (ម៉ាថាយ ១០:៣៨-៣៩; ពេត្រុសទី១ ៥:៨, ៩) ដោយទប់ទល់នឹងអារក្ស អ្នកអាចធ្វើឲ្យព្រះយេហូវ៉ាសព្វព្រះហឫទ័យ ហើយនិងបង្ហាញថាអ្នកជួយរក្សាការពារព្រះអធិបតេយ្យភាពនៃទ្រង់ផង ។—សុភាសិត ២៧:១១



*សូមទប់ទល់និងសាតាំងដោយបន្តការរៀនសូត្រអំពីព្រះយេហូវ៉ា*